Special Representative
of the United Nations Secretary-General
for Human Rights in Cambodia

Représentant spécial
du Secrétaire-général des Nations Unies
pour les droits de l'homme au Cambodge

# "ដើម្បីស្ថាបនាសង្គមមួយគ្រប់គ្រងដោយច្បាប់ និង ការគោរពសិទ្ធិមនុស្ស"

សុន្ទរកថារបស់លោកឯកអគ្គរាជទូត ថូម៉ាស់ ហាំម៉ាប៊ឺក តំណាងពិសេស
របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ថ្លែងទៅកាន់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី ២០ ខែតុលា ឆ្នាំ ១៩៩៩

---

សម្តេចក្រុមព្រះព្រះប្រធានរដ្ឋសភា និងសមាជិករដ្ឋសភា ដ៏ឧត្តម

ទូលបង្គំខ្ញុំមានកិត្តិយសណាស់ដែលត្រូវបានទទួលការអញ្ជើញអោយមកថ្លែងសុន្ទរកថាថ្វាយ និងជូន សម្តេច ឯកឧត្តម លោកជំទាវទាំងអស់ នៅថ្ងៃនេះ ។ ក្នុងឋានៈជាតំណាងនៃមណ្ឌលនានារបស់សម្តេច ឯកឧត្តម លោកជំទាវ សម្តេច ឯកឧត្តម លោកជំទាវ គឺជាសម្លេងដ៏ជាទីទុកចិត្តនៃសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋកម្ពុជាដ៏ឧត្តម ។ ជាការពិតណាស់ដែលថា ក្នុងសេចក្តីប្រាថ្នាទាំងនេះ គឺមានសេចក្តីសង្ឃឹមចង់អោយមានសង្គមមួយដែលជនគ្រប់រូបអាចទទួលបាននូវភាពយុត្តិធម៌-ដោយមិនគិតពីឋានៈដើមកំណើត និងសង្គម ជនជាតិ ភេទ អាយុ ឬថាតើអ្នកឯងជាអ្នកក្រ ឬអ្នកមានឡើយ ។

ជាការពិតណាស់ថា ក្នុងឋានៈជាជនបរទេសម្នាក់ ការយល់ដឹងរបស់ទូលបង្គំខ្ញុំអំពីប្រពៃណី និងនិន្នាការបច្ចុប្បន្ននៅក្នុងសង្គមកម្ពុជា គឺនៅមានកំរិតនៅឡើយ ។ អាស្រ័យហេតុនេះ ទូលបង្គំខ្ញុំ សូមដាក់ខ្លួនដោយរាបសា ហើយមិនមានបំណងនឹងផ្តល់នូវមេរៀនអ្វីមួយនោះទេ ។ ផ្ទុយទៅវិញ ទូលបង្គំខ្ញុំសង្ឃឹមថានឹងអាចចែករំលែកជាមួយសម្តេច ឯកឧត្តម លោកជំទាវ ដោយសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុត នូវការចាប់អារម្មណ៍របស់ទូលបង្គំខ្ញុំ ក្រោយពីបានបំពេញការងារជាតំណាងពិសេសរបស់លោកអគ្គលេខាធិការទទួល



Ambassador Thomas Hammarberg
Stockholm P.O.Box 16121, S-10323, Stockholm, Sweden
Tel: (46 8) 405 5645 Fax: (46 8) 723 1176
E-mail: thomas.hammarberg@foreign.ministry.se
Phnom Penh Cambodia Office of the UN High Commissioner for Human Rights
# 16A, Mao Tse Tuong Blvd, Phnom Penh, Cambodia Mailing Address: P.O.Box 108, Phnom Penh, Cambodia
Tel: (855 23) 362 585, 362 797, 216 342 Fax: (855 23) 720 030, 212 579
E-mail: cohchr@worldmail.com.kh

បន្ទុកសិទ្ធិមនុស្ស អស់រយៈពេល ៣ ឆ្នាំកន្លះមកនេះ ។ ទូលបង្គំខ្ញុំ ក៏មានបំណងនឹងឆ្លុះបញ្ចាំងឱ្យឃើញផង ដែរ នូវបទពិសោធន៍មួយចំនួនពីប្រទេសនានាស្តីពីបញ្ហាដែលទូលបង្គំខ្ញុំដឹងថាសម្តេច ឯកឧត្តម លោកជំទាវ កំពុងប្រឈមមុខជាមួយ ។

អ្វីដែលបានកន្ត្រាក់អារម្មណ៍របស់ទូលបង្គំខ្ញុំជាស្រេចទៅហើយ នៅក្នុងដំណើរទស្សនៈកិច្ចលើកទី ១ របស់ទូលបង្គំខ្ញុំនោះ គឺវិនាសកម្មពោរពេញដោយក្តីវន្ទត់ដែលបង្កើតឡើងដោយពួកខ្មែរក្រហម ។ ទីកន្លែង ណាក៏ដោយដែលទូលបង្គំខ្ញុំបានទៅដល់ ទូលបង្គំខ្ញុំតែងបានជួបប្រជាពលរដ្ឋដែលបានបាត់បង់សមាជិកនៃក្រុម គ្រួសាររបស់ពួកគេ និងរូបគេផ្ទាល់បានទទួលរងនូវទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរនៅក្រោមរបបខ្មែរក្រហម ។ ទូល បង្គំខ្ញុំយល់ឃើញថាការសម្លាប់រង្គាលនេះ បានរារាំងដល់ការប៉ុនប៉ងដើម្បីស្ថាបនាឡើងនូវស្ថាប័នដ៏រឹងមាំមួយ នៅក្នុងសង្គមនៅពេលក្រោយមកទៀត ក្នុងនេះរួមមានការកសាងឡើងនូវប្រព័ន្ធតុលាការដ៏មានប្រសិទ្ធិភាព មួយផងដែរ ។ ជាក់ស្តែង ការនេះបានរួមចំណែកធ្វើឱ្យកើតមានឡើងនូវបាតុភូតនៃបញ្ហានិទណ្ឌភាព ។

នៅក្នុងពេលធ្វើដំណើរតាមជនបទ ទូលបង្គំខ្ញុំបានជួបពិភាក្សាជាមួយចៅក្រមនៅតាមតុលាការខេត្ត នានា ។ ចៅក្រមជាច្រើនបានកំណត់យ៉ាងច្បាស់នូវបញ្ហានានា ដែលពួកគេបានជួបប្រទះនៅក្នុងប្រព័ន្ធ តុលាការ ។ មានការឃ្លាតឆ្ងាយ៉ាងខ្លាំងនៅក្នុងក្របខ័ណ្ឌច្បាប់ ឧទាហរណ៍ដូចជាការពុំមានច្បាប់ស្តីពីនីតិវិធី ព្រហ្មទណ្ឌគឺជាការបន្ទុចបង្អាក់ដ៏ធ្ងន់ធ្ងរមួយ ។ អ្នកច្បាប់ជំនាន់ថ្មីបានបញ្ចប់ការសិក្សាហើយ ប៉ុន្តែនៅមាន ការខ្វះចន្លោះនូវការអប់រំនៅឡើយ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៅមិនទាន់បានបំពេញតួនាទីនាំមុខ របស់ខ្លួនឱ្យបានពេញលេញនៅឡើយទេ ក្នុងការត្រួតពិនិត្យប្រពន្ធ័តុលាការ រួមមានតាមរយៈការតែងតាំង និងការចាត់វិធានការផ្នែកវិន័យជាដើម ។ គេនៅតែមានភាពមិនច្បាស់លាស់ជានិច្ច ថាតើករណីណាត្រូវបញ្ជូន ទៅកាន់តុលាការយោធា ហើយករណីណាត្រូវបញ្ជូនទៅកាន់តុលាការស៊ីវិល ។

ចៅក្រមទាំងឡាយក៏បានលើកឡើងផងដែរអំពីបញ្ហាធនធាន ។ អត្ថបទច្បាប់សំខាន់ ៗ និងករណី សំរាប់ធ្វើការយោងនានា មិនចេះតែរកបានជានិច្ចកាលនៅក្នុងតុលាការខ្លួនឯងនោះទេ ។ ការសំរួលផ្សេង ៗ សំរាប់ធ្វើការស៊ើបអង្កេតមានកំរិត ក្នុងនេះរួមមានឧបករណ៍សំរាប់ធ្វើកោសល្យវិច្ច័យ និងមធ្យោបាយដឹក ជញ្ជូនទៅកាន់ទីកន្លែងដែលកើតមានឧក្រិដ្ឋកម្មជាដើម ។ ទាំងនេះបានរួមចំណែកក្នុងការធ្វើឱ្យកើតមានឡើង

នូវបញ្ហាដ៏ធ្ងន់ធ្ងរនៃការឃុំខ្លួនមុនការកាត់ទោសហួសរយៈពេលកំណត់ ។ អ្នកដែលត្រូវបានចាប់ខ្លួន ត្រូវដាក់ឱ្យនៅក្នុងពន្ធនាគាររង់ចាំការកាត់ទោស ហួសរយៈពេលអតិបរមា ៦ ខែ ដែលកំណត់ដោយច្បាប់ ។ ប្រាក់ខែរបស់បុគ្គលិកតុលាការនៅតែមានកំរិតទាបនៅឡើយ ទោះបីក្រោយពីមានការដំឡើងប្រាក់ខែកាលពីពេលថ្មី ៗ កន្លងទៅនេះក៏ដោយ ដែលការនេះអាចជំរុញឱ្យកើតមាននូវការស៊ីសំណូក ។ កត្តាទាំងអស់នេះបានរាំងដល់កិច្ចការដ៏សំខាន់ក្នុងការលើកតម្កើងនូវឋានៈរបស់ចៅក្រម និងកែលំអនូវលទ្ធភាពនៃបំពេញនូវការទទួលខុសត្រូវដ៏សំខាន់របស់ពួកគេ។

បញ្ហាមួយទៀតដែលបានលើកឡើងដោយចៅក្រមមួយចំនួននោះ គឺការខ្វះនូវការគោរពចំពោះឯក-រាជ្យភាពរបស់តុលាការ ។ អ្វីដែលបានកើតឡើងនោះ គឺថាកាលណាមានរឿងក្តីប្រឆាំងទៅលើនាយទាហានណាម្នាក់នោះ មិនអាចធ្វើការតាមដានបានទេ ពីព្រោះមានការគំរាមកំហែងដោយអាវុធប្រឆាំងទៅលើបុគ្គលិកតុលាការ ។ វាក៏មានកើតមានឡើងផងដែរ ដែលថាដីកាចាប់ខ្លួនមិនត្រូវបានអនុវត្តដោយកងរាជអាវុធហត្ថ ពីព្រោះជនល្មើសបានទទួលការការពារពីថ្នាក់ស្រុកជាដើម ។ ជាការពិតណាស់ ការនេះគឺជាការប៉ះពាល់ធ្ងន់ធ្ងរមួយដល់ការខិតខំដើម្បីស្ថាបនាឡើងនូវសង្គមមួយដែលគ្រប់គ្រងដោយច្បាប់។

អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺថានៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន រាជរដ្ឋាភិបាលបានសន្យាថានឹងធ្វើការកែទំរង់ប្រពន្ធ័តុលាការ ។ ទូលបង្គំខ្ញុំបានទទួលពត៌មានអំពីផែនការនានារបស់ក្រសួងយុត្តិធម៌ ស្តីពីច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ លក្ខន្តិកៈរបស់ចៅក្រម និងលក្ខន្តិកៈរបស់ក្រឡាបញ្ជី ដែលច្បាប់ទាំងអស់នេះមានសារសំខាន់ណាស់សំរាប់ការប្រព្រឹត្តិទៅដោយត្រឹមត្រូវនៃប្រពន្ធ័តុលាការ ។ បើសិនជារាជរដ្ឋាភិបាលត្រូវការជំនួយ និងការផ្តល់យោបល់ថែមទៀតសំរាប់ការងារកែទំរង់ដ៏សំខាន់នេះ ទូលបង្គំខ្ញុំមានសេចក្តីរីករាយនឹងជួយពន្យល់អំពីសភាពការណ៍នេះដល់អ្នកផ្តល់ជំនួយអន្តរជាតិនានា ។

នៅក្នុងប្រទេសនិមួយ ៗ មានការត្រូវការឱ្យមានវិធានការដាច់ខាតដើម្បីស្ថាបនាឡើង នៅក្នុងការអនុវត្តន៍ នូវគោលការណ៍ជាមូលដ្ឋាននៃសមភាពនៅចំពោះមុខច្បាប់ ។ អាស្រ័យហេតុនេះ គឺជាការសំខាន់ណាស់ដែលកាលពីពេលថ្មី ៗ នេះ រដ្ឋសភាបានធ្វើវិសោធន៍កម្មលើមាត្រាទី ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ហើយសង្ឃឹមថាការផ្លាស់ប្តូរនេះនឹងត្រូវបានយល់ជ្រួតជ្រាប និងនាំទៅឱ្យមានការអនុវត្តន៍

ថ្មីជាពុំខាន ។ មាត្រាទី ៥១ ចាស់ បានរារាំងភាពយុត្តិធម៌នៅក្នុងករណីមួយចំនួន ហើយស្ទើរតែក្លាយទៅជានិមិត្តរូបនៃនិទណ្ឌភាពទៅហើយ ។

កិច្ចខិតខំបន្ថែម និងដោយស្មោះ ត្រូវការទាមទារឱ្យមានឡើង ដើម្បីធ្វើការស៊ើបអង្កេត និងនាំខ្លួនទៅកាន់តុលាការ នូវអ្នកទាំងឡាយណាដែលទទួលខុសត្រូវចំពោះអំពើហឹង្សាទាក់ទិនទៅនឹងនយោបាយដ៏ធ្ងន់ធ្ងរ ដែលបានកើតមានឡើងនៅក្នុងយៈពេលថ្មី ៗ កន្លងទៅនេះ ។ ការដែលពុំមាននរណាម្នាក់ត្រូវបានចាប់ខ្លួន និងផ្តន្ទាទោស ចំពោះការវាយប្រហារដោយគ្រាប់បែកដៃនៅខាងក្រៅអាគារនេះ កាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៩៧ ឬចំពោះឃាតកម្មលើរូបរដ្ឋលេខាធិការ ហូ សុខ នៅក្នុងខែកក្កដា នៃឆ្នាំដដែលនេះ-នេះដោយលើកឡើងតែឧទាហរណ៍ចំនួន ២ ប៉ុណ្ណោះ- គឺជាការប៉ះពាល់ដល់ការគោរពចំពោះប្រព័ន្ធតុលាការ ។ បទពិសោធន៍ពីប្រទេសនានាដ៏ទៃទៀត បានបង្ហាញឱ្យឃើញថាគឺជាការសំខាន់ណាស់ដែលថាការស៊ើបអង្កេតទៅលើករណីទាំងនោះត្រូវតែធ្វើឡើងហ្មត់ចត់ ប្រកបដោយតម្លាភាព និងត្រូវតែបានដល់សេចក្តីសន្និដ្ឋានមួយ ។ ការខកខានមិនបានធ្វើដូច្នេះ គឺជាការប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់អត្ថន័យនៃពាក្យថាយុត្តិធម៌របស់ប្រជាពលរដ្ឋ ។

ជនកម្ពុជាជាច្រើនរូបក៏បានប្រាប់ទូលបង្គំខ្ញុំផងដែរ អំពីសារសំខាន់នៃការដែលថា ពួកអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត នៅក្នុងរយៈពេលនៃរបបគ្រប់គ្រងខ្មែរក្រហមត្រូវបាននាំខ្លួនយកទៅកាត់ទោស ។ គោលជំហរនោះ -ដូចដែលបានលើកឡើងដោយនាយករដ្ឋមន្ត្រីទាំងពីរ កាលពីខែមិថុនា ឆ្នាំ១៩៩៧ កន្លងទៅនេះ- ត្រូវបានទទួលការគាំទ្រដោយមហាសន្និបាតអង្គការសហប្រជាជាតិ ។ កិច្ចចរចាររវាងក្រុមអ្នកជំនាញការច្បាប់អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកំពុងតែដំណើរការជាបន្ត ហើយទូលបង្គំខ្ញុំមិនចង់ចូលជ្រៀតជ្រែកទៅក្នុងកិច្ចការនេះទេ ។ ទូលបង្គំខ្ញុំគ្រាន់តែសូមអនុញ្ញាតដើម្បីបញ្ជាក់ជាថ្មីថា សហគមន៍អន្តរជាតិបានរៀបចំខ្លួនហើយដើម្បីជួយដល់ការកាត់ទោសមួយ ដែលសមស្របនឹងទៅបទដ្ឋានចាំបាច់នានានៃភាពយុត្តិធម៌ ភាពត្រឹមត្រូវ និងស្របទៅតាមនីតិវិធីច្បាប់ ។

កិច្ចដំណើការមួយបែបនេះ គឺជាការសំខាន់ណាស់សំរាប់វិញ្ញាណក្ខន្ធនៃអ្នកដែលត្រូវបានសម្លាប់ សំរាប់ញាតិសណ្តានរបស់ពួកគេ ហើយនឹងក៏ជាការព្រមានមួយចំពោះជំនាន់ក្រោយ ៗ តទៀតផងដែរ ។

ការនេះវានឹងជាមធ្យោបាយដ៏មានប្រសិទ្ធិភាពបំផុត ដើម្បីបង្ហាញអោយឃើញថា ជានិច្ចកាលនៅទីចុងបំផុត យុត្តិធម៌ត្រូវតែកើតមានឡើង ទោះបីជាជនល្មើសជាអ្នកណាក៏ដោយ ។ មេរៀនពីបណ្តាប្រទេសដទៃទៀត ដែលមានប្រវត្តិសាស្រ្តដ៏សាហាវ និងប្រកបដោយសោកនាដកម្ម នាពេលថ្មី ៗ កន្លងទៅនេះ- ដូចជា ប្រទេសអាល្លឺម៉ង់ អាហ្វ្រិកខាងត្បូង ស៊ីលី និងអាមេរិកកណ្តាល ជាដើម -បានបង្ហាញឱ្យឃើញថា មុខរបួសនឹងនៅតែចំហជានិច្ច រហូតដល់ការពិតត្រូវបានលាតត្រដាងឱ្យដឹង ថាឧក្រិដ្ឋកម្មត្រូវតែទទួលការផ្តន្ទាទោសផងដែរចំពោះករណីមិនមែននយោបាយ ។ បើសិនជាពិរុទ្ធជនអាចគេចពីការផ្តន្ទាទោស តាមរយៈការរត់គេចខ្លួន ឬការប្រើប្រាស់ការទាក់ទងជាមួយថ្នាក់លើបាននោះ សាធារណៈជនអាចនឹងគិតថា ផ្លូវតែមួយគត់សំរាប់ទទួលបានយុត្តិធម៌គឺយកច្បាប់មកកាន់នៅក្នុងដៃរបស់ខ្លួនផ្ទាល់តែប៉ុណ្ណោះ ។ របាយការណ៍ថ្មី ៗ នានា ស្តីពីហ្វូងមនុស្សចាប់ចងអ្នកដែលពួកគេសង្ស័យថាជាឧក្រិដ្ឋជនដើម្បីជាការផ្តន្ទាទោស ដោយឥតដាក់ឱ្យតុលាការវិនិច្ឆ័យតាមនីតិវិធីច្បាប់ធម្មតា រហូតដល់វាយឱ្យស្លាប់តែម្តងនោះ គឺជាការព្រមានមួយដ៏ធ្ងន់ធ្ងរ ។

## សមាជិករដ្ឋសភាដ៏ឧត្តម

អត្ថន័យនៃពាក្យយុត្តិធម៌នៅក្នុងសង្គមនិមួយ ៗ ក៏ប៉ះពាល់ដល់ឥរិយាបថប្រចាំថ្ងៃរបស់បុគ្គលិកអ្នកអនុវត្តន៍ច្បាប់ផងដែរ ។ ការប្រើអំពើហឹង្សាដោយហួសហេតុនៅក្នុងពេលចាប់ខ្លួនមនុស្ស និងប្រព្រឹត្តកម្មឃង់ឃ្នុង ឬការប្រើទារុណកម្មនៅក្នុងពេលសួរចម្លើយ មិនត្រូវអត់ឱនឱ្យបានជាដាច់ខាត ។ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានប្រាប់ទូលបង្គំខ្ញុំអំពីការខិតខំនានា ដើម្បីធ្វើឱ្យកងកម្លាំងនគរបាលមានជំនាញខាងវិជ្ជាជីវៈ នៅពេលដែលកងកម្លាំងទាំងនេះនឹងត្រូវបានរៀបចំជាថ្មី និងកាត់បន្ថយ ។ ការរួមចំណែកបន្ថែមទៀតណាមួយដែលយើងខ្ញុំ ក្នុងឋានៈជាតំណាងសហគមន៍អន្តរជាតិ អាចផ្តល់ជូនបាន ដូចជាការអប់រំជាដើមនោះ យើងខ្ញុំមានសេចក្តីរីករាយនឹងយកមកពិចារណា ។ សកម្មភាពជាចំបងមួយ របស់ការិយាល័យសិទ្ធិមនុស្ស អង្គការសហប្រជាជាតិនៅទីនេះ ច្បាស់លាស់ណាស់ គឺជួយឧបត្ថម្ភដល់ការបណ្តុះបណ្តាលប្រភេទដូចជាសំរាប់កងនគរបាល -និងកងយោធា នេះឯង ។

ការប្រើប្រាស់អាវុធដោយកងកម្លាំងនគរបាល -និងដោយបុគ្គលិកយោធា ពេលខ្លះនៅក្រៅពីម៉ោងធ្វើការផង- គឺជាបញ្ហានៃការព្រួយបារម្ភមួយរបស់មនុស្សជាច្រើន តាមដែលខ្ញុំបានដឹង ។ សង្វាក់នៃការបាញ់

ប្រហាររហូតដល់ស្លាប់នៅក្នុងពេលចាប់ខ្លួន មានកំរិតខ្ពស់ ។ បំណងប្រាថ្នាដ៏មុតមាំរបស់សម្តេចនាយករដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងការពារជាតិ ក្នុងការគ្រប់គ្រងអាវុធ និងទប់ស្កាត់នូវការប្រើប្រាស់វាដោយខុសច្បាប់នោះ ត្រូវបានទទួលការស្វាគមន៍ ជាប្រាកដណាស់ ។

បញ្ហាសន្តិសុខរបស់មនុស្សក៏មានទាក់ទៅនឹងលទ្ធភាពនៃការរស់ប្រចាំថ្ងៃផងដែរៈ សិទ្ធិមានរបររកស៊ី ទទួលបានការព្យាបាលនៅពេលមានជម្ងឺ និងអាចបញ្ជូនកូនទៅសាលារៀន ។ និយមន័យនៃពាក្យសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ មានរួមទាំងសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច ផង ។

ការកែលំអត្រូវបានធ្វើឡើងហើយ ក្នុងវិស័យនៃសិទ្ធិក្នុងការទទួលបាននូវការថែរក្សាសុខភាព ។ អត្រាស្លាប់របស់កុមារបានថយចុះយ៉ាងច្រើន ប៉ុន្តែនៅតែស្ថិតខ្ពស់ក្នុងកំរិតប្រមាណ ៩០ នាក់ ក្នុងកំណើត ១000 នាក់ ។ កុមារប្រមាណចំនួនពាក់កណ្តាលនៃកុមារទាំងអស់ ត្រូវបានរាយការណ៍មកថាមានការខ្វះអាហារ ហើយមានការរីករាលដាលនៃការគ្រិនមិនធំ និងការស្គមរីងរៃ ។ អត្រានៃការស្លាប់របស់មាតាក្នុងពេលសំរាលកូនមានកំរិតខ្ពស់ ហើយក្នុងមួយឆ្នាំ ៗ មានស្ត្រីចំនួន ២000 នាក់បានស្លាប់នៅពេលមានផ្ទៃពោះ និងពេលសំរាលកូន ។ មានការរីករាលដាលជាទូទៅយ៉ាងខ្ពស់នៃការឆ្លងមេរោគ HIV/AIDS ដែលនាំឱ្យមានបច្ច័យយ៉ាងធ្ងន់ធ្ងរនៅក្នុងរយៈពេលដ៏ខ្លី ។ ក៏ប៉ុន្តែ ទូលបង្គំខ្ញុំមានការស្ញើចសរសើរដល់ផែនការស្វាហាប់របស់ក្រសួងសុខាភិបាល។

លើសពី ១ ភាគ ៥ នៃកុមារអាយុពី ៦ ដល់ ១១ ឆ្នាំ នៅតែស្ថិតនៅក្រៅសាលានៅឡើយ ។ អត្រានៃការបោះបង់ចោលការសិក្សា និងនៃការរៀនត្រួតថ្នាក់មានកំរិតខ្ពស់ ។ កុមារពិការត្រូវប្រឈមមុខនឹងលទ្ធភាពជាពិសេសនៃការបដិសេធចេញពីប្រពន្ធ័សិក្សា ។ នៅតាមខេត្តដាច់ស្រយាល អត្រានៃការចុះឈ្មោះចូលរៀនមានចំនួនតិចជាង ៥0 ភាគរយ ។ ប្រពន្ធ័អប់រំទាំងមូលត្រូវរងនូវការខ្វះខាតនូវធនធាន ហើយនិន្នាការបច្ចុប្បន្នឆ្ពោះទៅរកការធ្វើឯកជនភាវូបន័យកម្ម អាចបង្កើតឱ្យមានចន្លោះកាន់តែធំថែមទៀតនៃការចាញ់ប្រៀបនៃកុមារក្រីក្រ ។ ទូលបង្គំខ្ញុំបានពិភាក្សាជាមួយនឹងរដ្ឋាភិបាលដ៏ទៃទៀត អំពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិជាបន្ថែមទៀត ដើម្បីជួយដល់ការកែទម្រង់អប់រំនៅក្នុងប្រទេសកម្ពុជា ។ ក្រសួងអប់រំក៏មានផែនការសំខាន់ ៗ ផងដែរ ។

ទូលបង្គំខ្ញុំមានសេចក្តីរំភើបយ៉ាងខ្លាំងចំពោះសិទ្ធិខ្លះរបស់កុមារ ។ សូមអនុញ្ញាតឱ្យទូលបង្គំខ្ញុំបន្ថែមអ្វីបន្តិចស្តីពីសិទ្ធិរបស់ស្ត្រី ។ ដូចដែលយើងទាំងអស់គ្នាធ្លាប់បានដឹងហើយថា មាននិន្នាការទូទាំងសកលលោកមួយនៃការទទួលស្គាល់ថា ត្រូវការឱ្យមានការកែទម្រង់ជាបន្ទាន់ដើម្បីទប់ស្កាត់ការរំលោភលើស្ត្រីភេទ និងដើម្បីលើកស្ទួយនូវឋានៈ និងឥទ្ធិពលរបស់ពួកគេនៅក្នុងសង្គម ។ នេះគឺជាការតស៊ូសំរាប់យើងទាំងអស់គ្នា មិនមែនតែសំរាប់តែសកម្មជនជាស្ត្រីប៉ុណ្ណោះទេ ។ ទូលបង្គំខ្ញុំទទួលបាននូវការលើកទឹកចិត្តដោយបានដឹងនៅទីនេះក្នុងប្រទេសកម្ពុជា អំពីបញ្ហានៃហឹង្សាក្នុងគ្រួសារ ។ ពុំមានការសង្ស័យអ្វីឡើយ គឺវាមានសេចក្តីត្រូវការឱ្យចាត់វិធានការបន្ថែមទៀតប្រឆាំងនឹងអំពើដ៏កំសាកនៃការវាយដំទៅលើស្ត្រី និងកុមារ -ដែលជាបញ្ហាមួយដែលបានរីករាលដាលគួរឱ្យព្រួយបារម្ភនៅទូទាំងសកលលោក ។ ទូលបង្គំខ្ញុំមានសេចក្តីស្ញើចសរសើរ ចំពោះផែនការនានាដែលបានលើកឡើងដោយរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន -ដែលរូបលោកជំទាវផ្ទាល់ គឺជាយុទ្ធនារីជើងចាស់មួយរូបក្នុងការប្រយុទ្ធទាមទារសិទ្ធិរបស់ស្ត្រីភេទ ។

បញ្ហាជនជាតិភាគតិចក៏សុទ្ធសឹងតែជាការព្រួយបារម្ភខាងផ្នែកសិទ្ធិមនុស្សជានិច្ចកាលផងដែរ ។ ទូលបង្គំខ្ញុំបានទៅបំពេញទស្សនៈកិច្ចនៅតាមភូមិនានារបស់ប្រជាពលរដ្ឋតំបន់ខ្ពង់រាប នៅក្នុងខេត្តរតនៈគិរី ហើយបានដឹងអំពីបញ្ហារបស់ពួកគេ និងការព្យាយាមរបស់ពួកគេដើម្បីដោះស្រាយនូវបញ្ហាទាំងនោះ ។ ដូចសម្តេចឯកឧត្តម លោកជំទាវ ធ្លាប់បានជ្រាបហើយថា បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនរបស់ពួកគេ គឺទាក់ទិននៅនឹងបញ្ហានៃការប្រើប្រាស់ និងសិទ្ធិលើដីធ្លី ។ នេះគឺជាទិដ្ឋភាពមួយនៃការពិភាក្សា នៅពេលដែលរដ្ឋសភានឹងពិភាក្សាលើពង្រាងច្បាប់ភូមិបាលថ្មី ។ បញ្ហារបស់ជនជាតិភាគតិចដ៏ទៃទៀត ទូលបង្គំខ្ញុំបានស្នើសុំឱ្យមានការបំភ្លឺមួយចំពោះឋានៈនៃប្រជាពលរដ្ឋដែលមានដើមកំណើតវៀតណាម ហើយដែលបានរស់នៅក្នុងប្រទេសនេះជាយូរមកហើយ ប្រហែលជាបានកើតនៅទីនេះផង និងបានចាត់ទុកប្រទេសកម្ពុជាថាជាផ្ទះសម្បែងរបស់ពួកគេទៅហើយ ។ ទូលបង្គំខ្ញុំមានការសោកស្តាយចំ ពោះការធ្វើអោយផុសឡើងនូវការស្អប់ជនបរទេស ការរំជើបរំជួលប្រឆាំងជនជាតិវៀតណាម ហើយសូមកោតសរសើរចំពោះអ្នកនយោបាយណាដែលប្រកាន់យកគោលជំហរជាគោលការណ៍ ប្រឆាំងនឹងឥរិយាបទបែបនេះ ។

សិទ្ធិមនុស្សទាក់ទិននឹងជនគ្រប់រូប ។ ទោះបីជាអ្នកនោះឯងបានបាត់បង់នូវសេរីភាពរបស់ពួកគេដោយសារអំពើឧក្រិដ្ឋណាមួយរបស់គេ ក៏គេត្រូវតែមានសិទ្ធិដែរ ។ ទូលបង្គំខ្ញុំបានទៅទស្សនាពន្ធនាគារមួយ

ចំនួននៅក្នុងប្រទេសកម្ពុជា ពន្ធនាគារជាច្រើនមានបញ្ហាដ៏ធំសម្បើមទាក់ទងនឹងម្ហូបអាហារ ការថែទាំសុខភាព និងបញ្ហាដទៃទៀត ប៉ុន្តែក៏មានបញ្ហាអគារដែលពិបាកនឹងទប់ស្កាត់នូវការលួចរត់គេចខ្លួនផងដែរ ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានប្រាប់ទូលបង្គំខ្ញុំអំពីផែនការពិនិត្យឡើងវិញនូវពន្ធនាគារនិមួយ ៗ នៅក្នុងប្រទេស ។ ការផ្តួចផ្តើមគំនិតនេះអាចនឹងត្រូវល្អប្រសើរឡើងថែមទៀត បើសិនជាសមាជិកនៃរដ្ឋសភានេះអញ្ជើញទៅទស្សនាពន្ធនាគារដែលស្ថិតនៅក្នុងមណ្ឌលរបស់ខ្លួនរៀង ៗ ខ្លួន

## សមាជិករដ្ឋសភាដ៏ឧត្តម

ទាំងអស់នេះ គឺសុទ្ធតែជាឧទាហរណ៍នៃបញ្ហាដែលទូលបង្គំខ្ញុំបានលើកមកពិភាក្សាជាមួយមន្ត្រីរដ្ឋាភិបាល បុគ្គលិកតុលាការ និងតំណាងគណបក្សនយោបាយ និងអង្គការក្រៅរដ្ឋាភិបាល ក៏ដូចជាជាមួយមិត្ត និងអ្នកគាំទ្ររបស់ប្រទេសកម្ពុជានៅឯនាយសមុទ្រ ។ ជាការពិតណាស់ ទូលបង្គំខ្ញុំមិនមានបំណងមើលស្រាលចំពោះបញ្ហាឡើយ ដែលបញ្ហាជាច្រើននៃបញ្ហាទាំងនោះមានលក្ខណៈធំសម្បើមអស្ចារ្យ និងតំរូវអោយមានទាំងការប្តេជ្ញាចិត្តខាងនយោបាយដ៏ខ្លាំងក្លា និងទាំងធនធានដ៏ទៃទៀតដ៏ច្រើនលើសលប់ផង ។ ទោះបីជាការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដោយមានការយល់ព្រមពីរដ្ឋាភិបាល នឹងបន្តកម្មវិធីរបស់ខ្លួនយ៉ាងហោចណាស់ក៏សំរាប់រយៈពេល ២ ឆ្នាំតទៅមុខទៀតក៏ដោយ ក៏វិភាគទានមកពីខាងក្រៅវា គ្រាន់ជាការបន្ទាប់បន្សំប៉ុណ្ណោះ ។ ការសំរេចរបស់សម្តេច ឯកឧត្តម លោកជំទាវ និងរបស់រដ្ឋាភិបាល ដែលសម្តេច ឯកឧត្តម លោកជំទាវ បានគាំទ្រនោះ - នឹងកំណត់នូវជំហានឆ្ពោះទៅរកសង្គមមួយដែលគ្រប់គ្រងដោយច្បាប់ និងការគោរពសិទ្ធិមនុស្ស ។

ទូលបង្គំខ្ញុំមានជំនឿជឿជាក់ថា ទ្រព្យសម្បត្តិលេខ ១ ដែលសម្តេច ឯកឧត្តម លោកជំទាវ មាននៅពេលជួបប្រទះនឹងការសាកល្បងនេះ គឺការផ្សព្វផ្សាយឱ្យបានយ៉ាងទូលំទូលាយនូវការយល់ដឹង ក្នុងចំណោមប្រជាពលរដ្ឋធម្មតា អំពីសារសំខាន់នៃសិទ្ធិ-ប្រហែលជាមួយចំណែក បណ្តាលមកពីប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនៃប្រវត្តិសាស្ត្រនាពេលថ្មី ៗ កន្លងទៅនេះ ។ ជាលទ្ធផល ការយល់ដឹងនេះគឺជាមូលដ្ឋានសំរាប់ការអភិវឌ្ឍន៍នូវ

ភាព ចាស់ តា និងប្រកបដោយកាៈឧ់ស សហៈ មន៏ក្រៅរដ្ឋា បាលសំរាប់ ទ្ធិមនុស្ស និងការ អ វិឌ្ឍ អៈ កា ស៊្វ័គ្រចិ ទានារបស់សម្ដេច ឯកឧៈ ម លោកជំទាវ គឺជាគំរូមួយសំរាប់ប្រទេសដ៏ ទទៀ

អៈ កា ទាំង នះនឹងមានសា សំខានសំរាបកា ស្ថាបនាទាពេល នា តេ វិសង្គមមួយដែលគោរព មនុស្ស ដូចជាសំលេងសា ពិសេ និង ទូល សត្រៀជាដើម លោ ក កាៈសិទ្ធិ ស្ស ទាំងរបស់ សភា ទាំង បសព្រឹ សភា នឹងបៃ មទំហំទៃសិ មនុស្ស ទាលើកាៈងា ស់ស មួច លោ ជំទា ងកា អៈ មតិច្បាបទាំឡាយ កគេ អាច ស្នើសុំ បាយកា ហើពីសំណា រដ្ឋា បាល ស្ដីពីបញ្ហ ទ្ធិមនុស្ស កានផងដៈ លា ភាព មួយ កាៈកាៈពិភាក្សា កាៈអ តេ និងអៈ សាធរ សំ ណា គម្មា កាៈសន្និសញ្ញា រជា នានា ក្រោយ កេ បា ពិនិត្យ បាយកាៈហើរបស់ប្រ ស ជារួចទោះ

នាងភា រដ្ឋាភិបាល មា កិច្ច នានា ម្បីសំរបសំរួលកាៈ តេ គំនិ ខាងសិទ្ធិ ស រវាង ក្រសួងនានា ក្នុង មមានជាមួយការិយាល័យរបស់ស ម្ដចនាយ ន្ត្រីផង ទូលពង្គំខ្ញុំក៏បានទទួល ហើងផង ពីផែ កាៈនានា ម្បីពង្រឹកកាៈសំៈបសំ លនេ ឱ្យទៅ លថ្នាក់ និងថ្នា មូលដ្ឋា

បៈ ពិសោ ប្រទេសនានាដ៏ ឲ្ បា ប្រាប់ៗយើ ថា ក្រៅ រចនាសម្ព័ន្ធទាំង នះ វាអា ជា កាៈមានប្រយោជន៍ ក្នុងបេ ឡើងៈ វិកា ឃាល័យឯករាជ្យមួយ ម្បីត្រួតពិនិត្យបញ្ហាសិ ទ្ធុស្សដោយ លេ លរដ្ឋា ពាក្យ លើងផ្សេ ត្រូ លេ លើកាៈ ក្សាដោយស ស្ដីអំពីផាៈ ប្រពន្ធ័ទាំង លេ លើ កាៈយ៉ាងដូច មួច គណៈ ម្មកា ជា កសំ សំ លាបែបនេ ស្ថិ មាមមិក្នុងប្រទេសជា ច្រើ នាពេលស ថ្វ មវៀ យ ពេកគេទាំងៈ នះនោះ ជាមួរមា កាៈប្រុងប្រយ័ ក្នុងការរៀបចំ កេ តឡើងៈ កា កាពេ កេ កេ ដែល ធ្វើឡើងដោយពលរលើ លរដ្ឋានេច្បាប់ណាមួយ និងត្រូវ ធានាភា ឯករាជ្យភា តេប្រាកដរបស់វា ដោយរាប់ទាំងរបៀ បប ការជ្រើសរើ សបុគ្គលិ និងនៃកាៈ ធរិកា ផងដែ

សមាជិករដ្ឋសភាដ៏ឧត្តម

ពេលខ្លះ ការងារសិទ្ធិមនុស្សមានភាពចំរូងចំរាស់ណាស់ ។ ការនេះមិនមែនជាអ្វីគួរឱ្យភ្ញាក់ផ្អើលនោះទេ ។ ទីបំផុត សិទ្ធិមនុស្សគឺជាធ្វើដែលទាក់ទងទៅនឹងអ្វី ៗ ដែលមានសារសំខាន់បំផុតនៃជីវិត - នោះគឺសេរីភាពផ្ទាល់ខ្លួនរបស់អស់លោកអ្នក ការការពារបូរណភាពរបស់អស់លោកអ្នក និងការបំពេញនូវសេចក្តីត្រូវការជាមូលដ្ឋានរបស់លោកអ្នក ។ សិទ្ធិមនុស្សក៏បានដាក់កំណត់ព្រំដែនដល់អ្នកកាន់អំណាចដងដែរ ចំពោះរបៀបរបបគ្រប់គ្រងរបស់ពួកគេ ។

មានការកើតឡើងនូវកំហឹងប្រឆាំងទៅនឹងរបាយការណ៍ស្តីពីបញ្ហាសិទ្ធិមនុស្ស ដែលបានតម្រង់ទិសឆ្ពោះទៅប្រឆាំងនឹងអ្នកនាំសារ ជាជាងប្រឆាំងទៅនឹងបញ្ហាទាំងនោះផ្ទាល់ទៅវិញ ។ ការណ៍នេះអាចនឹងយល់បាន ប៉ុន្តែវាមិនបានជួយអ្វីទេ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ទូលបង្គំខ្ញុំយល់ថាសង្គមកម្ពុជាមានការរីកចំរើនទៅមុខកាន់តែឆ្ងាយហើយ ។ មានបំណងមួយក្នុងចំណោមមនុស្សជាច្រើន ដែលចង់ស្តាប់ការរិះគន់ - ដើម្បីដោះស្រាយបញ្ហា ។ ការពិភាក្សាដោយសេរីមួយក្នុងលក្ខណៈបែបនេះ នឹងបង្កើតអោយមានការគោរពដ៏ទូលំទូលាយមួយទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស ។

សូមថ្លែងអំណរព្រះគុណ និងអរគុណ សម្តេច ឯកឧត្តម លោកជំទាវ ចំពោះការយកចិត្តទុកដាក់ស្តាប់ ។